**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៨៣ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## នីតិវិធីនៃការចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិច

* * * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្ដីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

Downloaded from http://www.khmerlaws.com

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៥ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យ លេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យលេខ៤៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការបង្កើតគណៈកម្មការសុរិយោដី
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ០២ ខែធ្នូ ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៩

# ស ម្រេ ច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

### មាត្រា ១.-

អនុក្រឹត្យនេះ មានគោលដៅកំណត់គោលការណ៍ នីតិវិធី និងយន្តការសម្រាប់ចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ជាកម្មសិទ្ធិសមូហភាព ។

### មាត្រា ២.-

អនុក្រឹត្យនេះ មានគោលបំណងផ្តល់សិទ្ធិស្របច្បាប់ក្នុងការកាន់កាប់ដីធ្លីដល់សហគមន៍ជនជាតិដើមភាគតិច ធានាសុវត្ថិភាពនៃការកាន់កាប់ដីធ្លី និងការពារកម្មសិទ្ធិសមូហភាព ដោយរក្សានូវអត្តសញ្ញាណ វប្បធម៌ ទំនៀមទម្លាប់ និងប្រពៃណីល្អរបស់សហគមន៍ជនជាតិដើមភាគតិច ។

### មាត្រា ៣.-

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះសហគមន៍ជនជាតិដើមភាគតិច ដែលបានបង្កើតជានីតិបុគ្គលស្របច្បាប់ លើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

Downloaded from http://www.khmerlaws.com

មាត្រា ៤.—

វាក្យសព្ទដែលមានប្រើនៅក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចតទៅ :

**កម្មសិទ្ធិសមូហភាព** សំដៅដល់ដីធ្លីដែលជាកម្មសិទ្ធិរួមរបស់សហគមន៍ជនជាតិដើមភាគតិចមួយក្រុម ហើយកម្មសិទ្ធិនេះមិនមែនជាកម្មសិទ្ធិឯកជនដោយឡែកៗរបស់សមាជិកសហគមន៍នោះឡើយ ។ សមាជិកសហគមន៍ម្នាក់ៗ ឬគ្រួសារនីមួយៗនៃសហគមន៍ គ្មានសិទ្ធិចាត់ចែងដីជាកម្មសិទ្ធិសមូហភាពនេះទេ ។

**ដីលំនៅឋាន** សំដៅដល់ដីដែលសមាជិកសហគមន៍ជនជាតិដើមភាគតិចប្រើប្រាស់ ដើម្បីសាងសង់លំនៅឋានសម្រាប់ស្នាក់នៅ ឬរស់នៅជាអចិន្ត្រៃយ៍ (និវេសនដ្ឋាន) ។

**ដីបម្រុងចាំបាច់ក្នុងការដូរវេនដំណាំ ឬដីរៀបចំបម្រុងសម្រាប់ចម្ការពនេចរ ឬដីចម្ការវិលជុំ** សំដៅដល់ដីដែលសហគមន៍ជនជាតិដើមភាគតិចធ្លាប់បានប្រើប្រាស់កន្លងមកជាស្រែ ឬជាចំការ ក្នុងការដូរវេនដំណាំតាមប្រពៃណី ។

**ដីព្រៃអារក្ស** សំដៅដល់ទីកន្លែងដែលសហគមន៍ទុកសម្រាប់គោរពបូជា ឬសែនព្រេនតាមទំនៀមទម្លាប់ប្រពៃណី ។

**ដីកប់ខ្មោច** សំដៅដល់ទីកន្លែងដែលសហគមន៍ប្រើប្រាស់សម្រាប់បញ្ចុះសពទៅតាមប្រពៃណីរបស់ខ្លួន ។

**អាជ្ញាធររដ្ឋបាល** សំដៅដល់អាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរដែលមានអាណត្តិកាន់កាប់ដីរដ្ឋ ឬធនធានធម្មជាតិរបស់រដ្ឋ ក្នុងតំបន់នោះ ។

**គណៈកម្មាធិការសហគមន៍ ឬអាជ្ញាធរប្រពៃណី** សំដៅដល់ថ្នាក់ដឹកនាំសហគមន៍ ដែលត្រូវបានជ្រើសរើសដោយសមាជិកសហគមន៍ទាំងមូល ។

**អ្នកជិតខាង** សំដៅដល់ប្រជាពលរដ្ឋ ឬសហគមន៍ទាំងឡាយ ឬអាជ្ញាធរកាន់កាប់ដីរដ្ឋដែលមានព្រំប្រទល់ដីជាប់នឹងដីរបស់សហគមន៍ ដែលបានស្នើសុំចុះបញ្ជីដី ។

**ក្រុមការងារវាល** សំដៅដល់សមាជិកក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក មួយក្រុម ដែលប្រធានក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក បានចាត់តាំងឱ្យចុះធ្វើអត្តសញ្ញាណកម្ម ធ្វើផែនទីដីរដ្ឋ និងដីសហគមន៍នៅក្នុងឃុំ សង្កាត់នីមួយៗ ។

**ក្រដាសកាល់** សំដៅដល់ក្រដាសម្យ៉ាងសថ្លាហើយស្តើង ប្រើសម្រាប់ដាន ឬគូសប្លង់ ផែនទី ។

**ចរន្តការ** សំដៅដល់ការកត់ត្រាទុកជាប្រចាំក្នុងឯកសារសុរិយោដី នូវរាល់ការកែប្រែប្រួល ឬការផ្លាស់ប្តូរ ដោយយោងតាមឯកសារគតិយុត្ត ។

**សហគមន៍ដែលបានបង្កើតជានីតិបុគ្គល** សំដៅដល់សហគមន៍ជនជាតិដើមភាគតិចដែលបានចងក្រង និងចុះបញ្ជីទទួលស្គាល់ជាផ្លូវការ នៅក្រសួងមហាផ្ទៃ ។

## ជំពូកទី ២

## គោលការណ៍នៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច

មាត្រា ៥.—

គោលការណ៍ទូទៅ ដែលត្រូវអនុវត្តក្នុងការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច មានដូចតទៅ ÷

- ការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច គឺជាការចុះបញ្ជីដីទាំងអស់របស់សហគមន៍មួយ ជាកម្មសិទ្ធិ

Downloaded from http://www.khmerlaws.com

សមូហភាពនៅក្នុងប្លង់រួមតែមួយ

- វិញ្ញាបនបត្រសម្គាល់កម្មសិទ្ធិសមូហភាពដែលត្រូវចេញជូនសហគមន៍ ត្រូវបញ្ជាក់ឈ្មោះសហគមន៍ ទីតាំងសហគមន៍ លេខយោងទៅកប្លង់រួមដែលចង្អុលបង្ហាញនូវទីតាំង ទំហំ ព្រំប្រទល់ និយាមកានៃចំណែកដីដែលជាកម្មសិទ្ធិសមូហភាព និងមានបញ្ជាក់ប្រភេទនៃការប្រើប្រាស់ដី និងកំណត់សម្គាល់ផ្សេងៗ

- សហគមន៍ដែលបានបង្កើតជានីតិបុគ្គលស្របច្បាប់ មានលក្ខន្តិកៈដែលបានចុះបញ្ជី និងមានការទទួលស្គាល់ជាផ្លូវការ អាចដាក់ពាក្យសុំចុះបញ្ជីដីកម្មសិទ្ធិសមូហភាពបាន

- សហគមន៍ជានីតិបុគ្គលស្របច្បាប់ ដែលមានបទបញ្ជាផ្ទៃក្នុងសហគមន៍ចែងអំពីការគ្រប់គ្រង និងការប្រើប្រាស់ដីជាសមូហភាព ព្រមទាំងការកំណត់នូវល័ក្ខខ័ណ្ឌមួយចំនួន មានជាអាទិ៍ ការចាត់ចែងដីជាសមូហភាព ការប្រើប្រាស់ដីទៅតាមប្រភេទដី និងការសម្រុះសម្រួលកម្រិតសហគមន៍ក្នុងករណីវិវាទលើការប្រើប្រាស់ដីតាមបែបប្រពៃណី។

## ជំពូកទី ៣

## ដីដែលត្រូវចុះបញ្ជីជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច

**មាត្រា ៦.—**

ដីដែលត្រូវចុះបញ្ជីជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច មាន ÷

១- ដីឯកជនរបស់រដ្ឋ ដូចជា ÷

- ដីលំនៅឋាន ឬដីដែលសហគមន៍បានរៀបចំនិវេសនដ្ឋាន
- ដីដែលសហគមន៍ប្រកបរបរកសិកម្មប្រពៃណី មានដីដាំដុះដាក់ស្លែង ដីស្រែចម្ការ និង

២- ដីសាធារណៈរបស់រដ្ឋ ដែលបានចុះបញ្ជីរួចហើយជាមួយរដ្ឋ ដូចជា ÷

- ដីបម្រុងចាំបាច់ក្នុងការវិលវល់ដំណាំ ដែលបានទទួលស្គាល់ដោយអាជ្ញាធររដ្ឋបាល និងមានការព្រមព្រៀងពីអ្នកជិតខាង
- ដីព្រៃអារក្ស ដែលអាចមានមួយកន្លែង ឬច្រើនកន្លែងសម្រាប់សហគមន៍នីមួយៗ ដោយមានទំហំសរុបមិនលើសពី ០៧ ( ប្រាំពីរ ) ហិកតា
- ដីកប់ខ្មោច ដែលអាចមានមួយកន្លែង ឬច្រើនកន្លែងសម្រាប់សហគមន៍នីមួយៗ ដោយមានទំហំសរុបមិនលើសពី ០៧ ( ប្រាំពីរ ) ហិកតា។

**មាត្រា ៧.—**

ចំពោះដីរដ្ឋផ្សេងទៀតដែលសហគមន៍ជនជាតិដើមភាគតិចធ្លាប់ប្រើប្រាស់តាមបែបប្រពៃណីកន្លងមក ដូចជាដីព្រៃឈើសម្រាប់ការប្រមូលផលនៃអនុផលព្រៃឈើ កន្លែងប្រើប្រាស់ទឹក សហគមន៍អាចបន្តប្រើប្រាស់ និងអាស្រ័យផលតាមប្រពៃណីរបស់ខ្លួន ប៉ុន្តែត្រូវចុះកិច្ចព្រមព្រៀងជាមួយស្ថាប័នសាមីដែលមានអាណត្តិកាន់កាប់ដីរដ្ឋនោះ។

Downloaded from http://www.khmerlaws.com

## ជំពូកទី ៤

## នីតិវិធី និងយន្តការនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច

**មាត្រា ៨.—**

ប្រធានគណៈកម្មាធិការសហគមន៍ ឬអាជ្ញាធរប្រពៃណីជនជាតិដើមភាគតិចនីមួយៗត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីដីសហគមន៍ ជាកម្មសិទ្ធិសមូហភាពនៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ដែលដីតាំងនៅ ដោយប្រើប្រាស់គំរូពាក្យសុំដូចមានក្នុងឧបសម្ព័ន្ធទី ១ នៃអនុក្រឹត្យនេះ ។ នៅលើពាក្យសុំចុះបញ្ជីដីត្រូវមានការបញ្ជាក់ពីចៅសង្កាត់ មេឃុំ ថាសហគមន៍ដែលស្នើសុំចុះបញ្ជីដីពិតជាសហគមន៍ដែលស្ថិតនៅក្នុងសង្កាត់ ឃុំរបស់ខ្លួនប្រាកដមែន។

សំណុំលិខិតស្នើសុំចុះបញ្ជីដីសហគមន៍របស់សហគមន៍ជនជាតិដើមភាគតិច មានដូចតទៅ ÷

- ពាក្យស្នើសុំចុះបញ្ជីដីសហគមន៍មានផ្តិតមេដៃប្រធានគណៈកម្មាធិការសហគមន៍ ឬអាជ្ញាធរប្រពៃណី
- លិខិតប្រគល់សិទ្ធិជូនសមាជិកគណៈកម្មាធិការសហគមន៍ណាម្នាក់ជាតំណាងសហគមន៍ ក្នុងដំណើរការផ្តល់ព័ត៌មាន ការបំពេញទម្រង់បែបបទក្នុងការចុះបញ្ជីដីសហគមន៍តាមនីតិវិធីជាធរមាន ប្រសិនបើប្រធានគណៈកម្មាធិការសហគមន៍ ឬអាជ្ញាធរប្រពៃណីមិនអាចចូលរួមបាន
- លក្ខន្តិកៈរបស់សហគមន៍ និងបញ្ជីរាយនាមសមាជិកសហគមន៍មានសេចក្តីបញ្ជាក់ពីចៅសង្កាត់ មេឃុំ
- បទបញ្ជាផ្ទៃក្នុងរបស់សហគមន៍ ទាក់ទងនឹងរបៀបគ្រប់គ្រង និងការប្រើប្រាស់ដីជាសមូហភាព
- លិខិតជូនដំណឹងស្តីពីការយល់ព្រមឱ្យចុះបញ្ជីសហគមន៍ដោយក្រសួងមហាផ្ទៃ
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសង្កាត់ ឃុំស្តីពីការតែងតាំងគណៈកម្មាធិការសហគមន៍ និង
- រាល់ឯកសារពាក់ព័ន្ធនឹងដីដែលស្នើសុំចុះបញ្ជី ប្រសិនបើមាន។

**មាត្រា ៩.—**

ក្រោយពីបានទទួលពាក្យសុំចុះបញ្ជីដី ប្រសិនបើទីតាំង ទំហំ និងព្រំប្រទល់ដីរបស់សហគមន៍ជនជាតិដើមភាគតិចនោះមានការឯកភាពពីអ្នកជិតខាង ពីអាជ្ញាធររដ្ឋបាល និងមិនមានទំនាស់ ឬមានទំនាស់តែត្រូវបានដោះស្រាយរួចហើយ ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ត្រូវលើកសំណើជូនអភិបាលក្រុង ស្រុក ដើម្បីចេញសេចក្តីជូនដំណឹងជាសាធារណៈក្នុងរយៈពេល ២០ (ម្ភៃ) ថ្ងៃយ៉ាងតិច មុនកាលបរិច្ឆេទនៃការចុះកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ។ សេចក្តីជូនដំណឹងត្រូវបិទផ្សាយជាសាធារណៈនៅកន្លែងដែលងាយមើលឃើញ ដូចជា នៅទីស្នាក់ការភូមិ នៅសាលាសង្កាត់ ឃុំ ទីប្រជុំជន និងទីតាំងដីរបស់សហគមន៍សាមី។

ក្រោយពីមានការកំណត់ព្រំប្រទល់ និងវាស់វែងជាក់ស្តែង ទិន្នន័យដែលប្រមូលបានត្រូវបិទផ្សាយជាសាធារណៈ រយៈពេល ៣០ (សាមសិប) ថ្ងៃ នៅក្នុងសហគមន៍សាមី និងនៅសាលាសង្កាត់ ឃុំដែលសហគមន៍នោះស្ថិតនៅ។

Downloaded from http://www.khmerlaws.com

ក្រោយរយៈពេលបិទផ្សាយ និងក្រោយពីការតវ៉ាផ្សេងៗ ប្រសិនបើមាន ត្រូវបានដោះស្រាយរួចហើយ រដ្ឋបាលសុរិយោដីត្រូវដំណើរការចុះបញ្ជីដី និងចេញវិញ្ញាបនបត្រសម្គាល់កម្មសិទ្ធិសមូហភាព ជូនសហគមន៍តាមនីតិវិធីដូចមានចែងក្នុងមាត្រា ១០ នៃអនុក្រឹត្យនេះ ។

**មាត្រា ១០.–**

ក្នុងករណីដែលទីតាំង ទំហំ និងព្រំប្រទល់ដីរបស់សហគមន៍ជនជាតិដើមភាគតិចដែលស្នើសុំចុះបញ្ជី នៅមិនទាន់មានការឯកភាពពីអ្នកជិតខាង ឬពីអាជ្ញាធររដ្ឋបាល ត្រូវរៀបចំកិច្ចដំណើរការតាមរយៈយន្តការ និងនីតិវិធីដូចខាងក្រោម :

១- ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុកត្រូវលើកសំណើទៅអភិបាលក្រុង ស្រុក ដែលជាប្រធានក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ដើម្បីដំណើរការធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដីរដ្ឋ នៅតំបន់ដែលសហគមន៍ស្នើសុំចុះបញ្ជីដី ។

២- បន្ទាប់ពីបានទទួលសំណើ អភិបាលក្រុង ស្រុកត្រូវពិនិត្យ និងលើកយោបល់ជូនអភិបាលខេត្ត ជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្នុងរយៈពេលមិនលើសពី ១៥ (ដប់ប្រាំ) ថ្ងៃ សុំឱ្យក្រុមការងារដីរដ្ឋថ្នាក់ក្រុងស្រុកចុះធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដីរដ្ឋ និងដីរបស់សហគមន៍ នៅតំបន់ដែលសហគមន៍ស្នើសុំចុះបញ្ជី ។

៣- អភិបាលខេត្ត ត្រូវចាត់តាំងក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ប្រសិនបើមិនទាន់បានចាត់តាំង ដើម្បីអនុវត្តដំណើរការធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដីរដ្ឋ និងដីរបស់សហគមន៍ជនជាតិដើមភាគតិចដែលសុំចុះបញ្ជី ស្របតាមនីតិវិធីដូចមានចែងក្នុងមាត្រា ៦ និងមាត្រា ៧ នៃអនុក្រឹត្យលេខ ១១៨ ស្ដីពីការគ្រប់គ្រងដីរដ្ឋ ។

៤- ក្រោយពីទទួលបានយោបល់ឯកភាពពីអភិបាលខេត្ត ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ត្រូវជូនដំណឹងដល់ប្រជាពលរដ្ឋក្នុងសហគមន៍សាមី អ្នកជិតខាង និងអ្នកពាក់ព័ន្ធ យ៉ាងតិច ២០ (ម្ភៃ) ថ្ងៃ មុនពេលចុះធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដីរដ្ឋ និងដីសហគមន៍ ។

៥- ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ត្រូវរៀបចំកិច្ចប្រជុំកសាងបញ្ជីដីរដ្ឋ និងដីរបស់សហគមន៍ ដោយមានការចូលរួមពីអាជ្ញាធរប្រពៃណីរបស់សហគមន៍ ឬតំណាងរបស់សហគមន៍សាមី ដើម្បីធ្វើការគូសបង្ហាញទីតាំង ព្រំប្រទល់ និងទំហំដីរបស់ខ្លួននៅលើក្រដាសកាល់ដែលដាក់នៅលើផែនទីមាននិយាមកាច្បាស់លាស់ ។ អាជ្ញាធរកាន់កាប់ដីរដ្ឋក៏ត្រូវគូសបង្ហាញដីរដ្ឋនៅលើក្រដាសកាល់ផ្សេងទៀតដែលដាក់នៅលើផែនទីនេះដែរ ។

៦- បន្ទាប់ពីធ្វើការផ្ទៀងផ្ទាត់លទ្ធផលនៃការគូសបង្ហាញលើក្រដាសកាល់នានា ក្រុមការងារដីរដ្ឋថ្នាក់ក្រុងស្រុក ត្រូវដៅនូវចំណុចដែលគងជាន់គ្នា ឬមានភាពមិនច្បាស់លាស់មកពិភាក្សាគ្នា និងកំណត់ថ្ងៃចុះពិនិត្យរួមគ្នា រវាងក្រុមការងារវាល ដែលក្នុងនោះត្រូវមានវត្តមានមន្ត្រីនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក អាជ្ញាធរប្រពៃណីរបស់សហគមន៍ ប្រជាពលរដ្ឋក្នុងសហគមន៍ និង/ឬតំណាងរបស់សហគមន៍សាមី និងសហគមន៍ ឬប្រជាពលរដ្ឋនៅជិតខាង ក្នុងការកំណត់ទីតាំង ព្រំប្រទល់ និងទំហំដីដែលសហគមន៍បាន និងកំពុងកាន់កាប់ ឬប្រើប្រាស់ផ្សេងៗ ។

៧- ក្នុងការចុះពិនិត្យជាក់ស្ដែង ក្រុមការងារវាលអាចស្នើធ្វើការកែតម្រូវ ប្រសិនបើពិនិត្យឃើញថា ទីតាំង

Downloaded from http://www.khmerlaws.com

ព្រំប្រទល់ និងទំហំដី ដែលសហគមន៍បាន និងកំពុងកាន់កាប់ ប្រើប្រាស់ជាប្រពៃណីកន្លងមក ខុសពីការអះអាងដែលបានគូសលើផែនទី និងដោយមានការយល់ព្រមពីតំណាងសាមីសហគមន៍ និងសមាជិកសហគមន៍។ រាល់សំណើកែតម្រូវ ទោះបីមានការព្រមព្រៀងគ្នា ឬមិនមានការព្រមព្រៀង ក៏ត្រូវធ្វើកំណត់ហេតុ និងចុះហត្ថលេខា ឬផ្តិតមេដៃរបស់ភាគីពាក់ព័ន្ធទាំងអស់ និងមន្ត្រីក្រុមការងារវាល ។

៨- លទ្ធផលនៃការធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដែលត្រូវភ្ជាប់ជាមួយរបាយការណ៍ និងកំណត់ហេតុផ្សេងៗ ត្រូវដាក់ជូនក្រុមការងារជីវដ្ឋថ្នាក់ក្រុង ស្រុក ដើម្បីធ្វើការប្រជុំសម្របសម្រួលរកការឯកភាពគ្នា។

៩- លទ្ធផលសង្ខេបនៃការប្រជុំ និងផែនទីទីតាំង ព្រំប្រទល់ និងទំហំដីសហគមន៍ និងជីវដ្ឋ ត្រូវបិទផ្សាយជាសាធារណៈរយៈពេល ៣០ (សាមសិប) ថ្ងៃ នៅទីស្នាក់ការសហគមន៍ ទីស្នាក់ការភូមិ និងសាលាសង្កាត់ ឃុំ ដើម្បីរង់ចាំទទួលមតិសាធារណៈ។ ការផ្តល់មតិពីសាធារណជន នឹងត្រូវទទួលនៅសាលាសង្កាត់ ឃុំនៃសហគមន៍សាមី ។

១០- បន្ទាប់ពីការបិទផ្សាយជាសាធារណៈ លទ្ធផលនៃការធ្វើអត្តសញ្ញាណកម្ម ធ្វើផែនទីដីសហគមន៍ និងជីវដ្ឋ ព្រមទាំងរបាយការណ៍សង្ខេបមតិសាធារណៈ ត្រូវបញ្ជូនទៅសុំយោបល់សម្រេចពីគណៈកម្មាធិការគ្រប់គ្រងជីវដ្ឋថ្នាក់ខេត្ត ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ។

១១- គណៈកម្មាធិការគ្រប់គ្រងជីវដ្ឋថ្នាក់ខេត្តអាចចាត់តាំងក្រុមមន្ត្រីចុះស៊ើបអង្កេត និងសាកសួរព័ត៌មានបន្ថែម ក្នុងករណីដែលមានការអះអាងមិនស្របគ្នា ឬមានភាពមិនច្បាស់លាស់ដោយប្រការណាមួយ។

១២- ក្រោយពីការឯកភាពលើទីតាំង ព្រំប្រទល់ និងទំហំដី ដែលសហគមន៍បានសុំចុះបញ្ជី គណៈកម្មាធិការគ្រប់គ្រងជីវដ្ឋថ្នាក់ខេត្តត្រូវបញ្ជូនសេចក្តីសម្រេចនោះទៅក្រុមការងារជីវដ្ឋថ្នាក់ក្រុង ស្រុក ដើម្បីពិនិត្យ និងសម្រុះសម្រួលវិវាទផ្សេងៗ ប្រសិនបើមាន។ ក្នុងករណីដែលការសម្រុះសម្រួលមិនអាចស្វែងរកការឯកភាពគ្នាបាន ក្រុមការងារជីវដ្ឋថ្នាក់ក្រុង ស្រុកត្រូវបញ្ជូនសំណុំរឿងវិវាទនោះ ទៅគណៈកម្មការសុរិយោដី។

១៣- បន្ទាប់ពីការសម្រេចឯកភាពលើទីតាំង ព្រំប្រទល់ ទំហំដី និងដោះស្រាយវិវាទនានារួចហើយ ក្រុមការងារជីវដ្ឋថ្នាក់ក្រុង ស្រុកត្រូវប្រគល់ឯកសារពាក់ព័ន្ធនឹងដីដែលសហគមន៍បានស្នើសុំចុះបញ្ជី ទៅរដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ដើម្បីវាស់វែង និងចុះបញ្ជីចំណែកផ្សេងៗនៃដីសហគមន៍ តាមនីតិវិធីដូចមានចែងក្នុងមាត្រា ៩ នៃអនុក្រឹត្យនេះ និងបញ្ចូលទិន្នន័យជីវដ្ឋទៅក្នុងប្រព័ន្ធទិន្នន័យជីវដ្ឋ។

**មាត្រា ១១.–**

រដ្ឋបាលសុរិយោដី ត្រូវបង្កើតសៀវភៅគោលបញ្ជីដោយឡែក សម្រាប់ការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច។

រដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុកត្រូវចុះបញ្ជីដីសហគមន៍ដែលបានដាក់ពាក្យសុំជាកម្មសិទ្ធិសមូហភាព ក្នុងសៀវភៅគោលបញ្ជី ដោយផ្អែកលើទិន្នន័យដែលប្រមូលបាន ដូចមានចែងក្នុងមាត្រា ៩ នៃអនុក្រឹត្យនេះ ឬដោយផ្អែកលើលទ្ធផលនៃការធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដែលបានសម្រេចជាផ្លូវការ ដូចមានចែងក្នុងមាត្រា ១០ នៃអនុក្រឹត្យនេះ។

ការចុះបញ្ជីដីរបស់សហគមន៍ត្រូវចុះគ្រប់ចំណែកនៃក្បាលដីទាំងអស់របស់សហគមន៍មួយ នៅលើប្លង់រួមតែមួយ ទោះបីក្បាលដីទាំងនោះស្ថិតនៅក្នុងភូមិ ឃុំខុសគ្នាក៏ដោយ។ ផ្អែកលើប្លង់រួមនេះ រដ្ឋបាលសុរិយោដីត្រូវចេញវិញ្ញាបនបត្រសម្គាល់កម្មសិទ្ធិសមូហភាពជូនសហគមន៍ ទៅតាមស្ថានភាពជាក់ស្តែងនៃក្បាលដីនីមួយៗ ដោយបញ្ជាក់

Downloaded from http://www.khmerlaws.com

ឈ្មោះសហគមន៍ ទីតាំងសហគមន៍ លេខយោងទៅរកប្លង់រួមដែលចង្អុលបង្ហាញទីតាំង ទំហំ ព្រំប្រទល់ និយាមកានៃចំណែកដីដែលជាកម្មសិទ្ធិសមូហភាព និងមានបញ្ជាក់នូវប្រភេទនៃការប្រើប្រាស់ដី និងកំណត់សម្គាល់ផ្សេងៗ។ គំរូវិញ្ញាបនបត្រសម្គាល់កម្មសិទ្ធិសមូហភាពរបស់សហគមន៍មានទម្រង់ ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី ២ នៃអនុក្រឹត្យនេះ។

**មាត្រា ១២.—**

ក្នុងករណីក្រុមការងារដីរដ្ឋថ្នាក់ ក្រុង ស្រុក ចុះអនុវត្តការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ នៅកន្លែងដែលមានសហគមន៍ជនជាតិដើមភាគតិចរស់នៅ ហើយជាសហគមន៍បានចុះបញ្ជី និងបានទទួលស្គាល់ជាផ្លូវការដោយក្រសួងមហាផ្ទៃរួចហើយ ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុកត្រូវផ្សព្វផ្សាយឱ្យសហគមន៍នោះដាក់ពាក្យស្នើសុំចុះបញ្ជីដីកម្មសិទ្ធិសហគមន៍។ សហគមន៍ត្រូវចូលរួមបង្ហាញនូវទីតាំង ព្រំប្រទល់ និងទំហំនៃចំណែកដីផ្សេងៗដែលសហគមន៍បានកាន់កាប់ និងកំពុងប្រើប្រាស់ដល់ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ស្របតាមនីតិវិធីដែលមានចែងក្នុងមាត្រា ៩ និងមាត្រា ១០ នៃអនុក្រឹត្យនេះ។

## ជំពូកទី ៥

## លក្ខខណ្ឌក្នុងការទទួលបានដីនៅពេលសមាជិកសហគមន៍សុំចូល ឬសុំចេញ ពីសហគមន៍ និងការរំសាយសហគមន៍

**មាត្រា ១៣.—**

ជនជាតិដើមភាគតិចដែលបានកាន់កាប់ចំណែកដីជាឯកជនស្របច្បាប់ ឬមានដីជាកម្មសិទ្ធិឯកជន ហើយស្នើសុំចូលជាសមាជិកសហគមន៍ជនជាតិដើមភាគតិចណាមួយ នោះសាមីខ្លួនត្រូវលះបង់ចំណែកដីឯកជនរបស់ខ្លួនទាំងអស់មកដាក់បញ្ចូលជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ ហើយសមាជិកថ្មីនេះត្រូវទទួលបាននូវអត្ថប្រយោជន៍ផ្សេងៗពីសហគមន៍ដូចសមាជិកដទៃទៀតដែរ។

**មាត្រា ១៤.—**

នៅពេលដែលសមាជិកណាម្នាក់សម្រេចចាកចេញពីសហគមន៍ សាមីជននោះអាចនឹងត្រូវទទួលបាននូវចំណែកដីសមស្របដែលនឹងត្រូវកាត់ចេញពីដីកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ឬអាចទទួលបានជាសំណងទូទាត់សមស្រប ទៅតាមការសម្រេចរបស់សមូហភាពសហគមន៍ ក្នុងករណីដែលអ្នកចាកចេញយល់ព្រម។

ចំណែកដីដែលត្រូវកាត់ជូនសមាជិកចាកចេញពីសហគមន៍ អាចជាដីដែលសហគមន៍បានរៀបចំនិវេសនដ្ឋាន និង/ឬ ដីដែលសហគមន៍ប្រកបរបរកសិកម្មប្រពៃណី ដូចជាដីដាំដុះដាក់ស្ពែង និងដីស្រែចម្ការ។

ក្នុងការកាត់ចេញចំណែកដី ឬបញ្ចូលចំណែកដីរបស់សហគមន៍ជនជាតិដើមភាគតិចណាមួយ ដែលបណ្តាលមកពីមានសមាជិកសុំចាកចេញ ឬសុំចូលថ្មី តំណាងសហគមន៍ត្រូវស្នើសុំទៅរដ្ឋបាលសុរិយោដី ដើម្បីធ្វើការចុះបញ្ជីបន្តនូវរាល់ការផ្លាស់ប្តូរទាំងនោះ។

Downloaded from http://www.khmerlaws.com

**មាត្រា ១៥.—**

ក្នុងករណីដែលសហគមន៍ត្រូវរំសាយ ការចាត់ចែងទ្រព្យសម្បត្តិរបស់សហគមន៍ត្រូវអនុលោមតាមខ្លឹមសារនៃលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា ១៦.—**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៧.—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលរាជធានី និងអភិបាលខេត្តត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ ២០០៥

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

*កន្លែងទទួល*
*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
*-ដូចមាត្រា ១៧*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

Downloaded from http://www.khmerlaws.com